**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តកណ្តាល**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ២២៥ អក ចុះថ្ងៃទី ០៩

ខែ មិថុនា ឆ្នាំ ១៩៩៥

**ជំនុំជំរះ**

លេខ ០១ រ ចុះថ្ងៃទី ០៤

ខែ មករា ឆ្នាំ ១៩៩៦

**សាលក្រម**

លេខ ០១ រ ចុះថ្ងៃទី ០៤

ខែ មករា ឆ្នាំ ១៩៩៦

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តកណ្តាល**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ស[...] នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០[...] ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការខេ[...] នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៦ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

**ដើម្បីជំនុំជំរះ ៖**

-ជនជាប់ចោទឈ្មោះ ល ម ភេទស្រី អាយុ ៤៦ឆ្នាំ (ក្រៅឃុំ) [...] ឥស្លាម ជនជាតិចាម សញ្ជាតិកម្ពុជា ទីកន្លែងកំណើតភូមិទួលងោក ឃុំកំពង់ហ្ល[...] ពញាឮ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិទួលងោក ឃុំកំពង់លួង ស្រុកពញ[...] កណ្តាល ឪពុកឈ្មោះ ល (រ) ម្តាយឈ្មោះ គ ន (ស) ប្តីឈ្មោះ ម ឈ[...] ០២នាក់ ។

-ជនជាប់ចោទឈ្មោះ ល យ ភេទស្រី អាយុ ១៨ឆ្នាំ (ក្រៅឃុំ) [...] ឥស្លាម ជនជាតិចាម សញ្ជាតិកម្ពុជា ទីកន្លែងកំណើតភូមិទួលងោក ឃុំក[...] ស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិទួលងោក ឃុំកំពង់លួង ស្រុ[...] ខេត្តកណ្តាល ឪពុកឈ្មោះ ម ល (រ) ម្តាយឈ្មោះ ល ម (រ) នៅលីវ ។

-ជនជាប់ចោទឈ្មោះ ស អស ភេទស្រី អាយុ ៦៣ឆ្នាំ (ក្រៅឃុំ) [...] ឥស្លាម ជនជាតិចាម សញ្ជាតិកម្ពុជា ទីកន្លែងកំណើតភូមិទួលងោក ឃុំក[...] ស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិទួលងោក ឃុំកំពង់ហ្លួង ស្រុ[...] ខេត្តកណ្តាល ឪពុកឈ្មោះ អ ស (រ) ម្តាយឈ្មោះ ស ឧ នៅលីវ ។

-ជាប់ចោទពីបទ ៖ **បង្ករបួសស្នាមដោយចេតនា** ប្រព្រឹត្តនៅភូមិទ[...] ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១[...] បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៤១ [...] ព្រហ្មទណ្ឌសម័យអន្តរកាល ។

*សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៦ ដោយគូភាគីពុំបានចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

*កណ្តាល, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៦*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**អនុប្រធានតុលាការខេត្តកណ្តាល**

[redacted]



Scanned with CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៥ វេលាម៉ោង ៤:០០ទៀបភ្លឺ នាង **ស ឧ** និងកូនរបស់គាត់ចំនួន ០២នាក់ទៀតឈ្មោះ **ស អស.** ឈ្មោះ **ស គ** បានទៅសាមង ហើយបានជួបជាមួយនាង **ល ម** និងកូនរបស់គាត់ ០២នាក់ទៀតឈ្មោះ **ល យ** ឈ្មោះ **ល អស** កំពុងសាមង ហើយពេលសាមងនោះក៏មានការទាស់ទែងគ្នាពីរឿងវាយមងជិតគ្នា ហើយជំពាក់មងជាប់គ្នារហូតមានការវាយគ្នាទៅវិញទៅមករវាងក្រុមគ្រួសារនាង **ស ឧ** និងនាង **ល ម** ពេលវាយគ្នានោះនាង **ស ឧ** និងនាង **ល យ** ក៏ត្រូវរបួសទាំងសងខាង រួចក៏មកដេកព្យាបាលនៅមន្ទីរពេទ្យរៀង១ខ្លួន ។

-បានឃើញលិខិតលេខ : ២៣៧/៩៥ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៥ បញ្ជាក់ពីលទ្ធផលពិនិត្យជម្ងឺរបស់នាង **ល យ** ។

-បានឃើញវិញ្ញាប័ណ្ណប័ត្រពេទ្យលេខ : ៣៧៨/៩៥ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥ បញ្ជាក់ពីសភាពជម្ងឺរបស់នាង **ស ឧ** ។

-បានឃើញកំណត់ហេតុដកហូតវត្ថុតាង ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៥ របស់ប៉ុស្តិ៍នគរបាលព្រែកក្តាម ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ : ២៨៥ ដកសព.៩៥ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល ។

-បានឃើញដីកាបញ្ជូនរឿងឱ្យជំនុំជំរះលេខ : ២១៦ ដជរ.៩៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **ល ម** បានឆ្លើយថា : មុនដំបូងមានទំនាស់គ្នាពីរឿងវាយមងជាន់លើគ្នា ហើយនាង ស ទ ក៏ទាញក្តារមកគប់ខ្លួន តែពុំត្រូវខ្លួន ខ្លួនក៏ថាប្រយ័ត្នអញវាយវិញ នាង **ស ឧ** ក៏ឆ្លើយតប៉ម៉កវិញថាអញពោះធំពេលនោះខ្លួនក៏ទុកក្តារវិញ ស្រាប់តែនាង **ស ឧ** វាយកូនរបស់ខ្លួនឈ្មោះ **ល យ** បែកក្រចកដៃ រួចចាប់អូសដៃកូនរបស់ខ្លួនឱ្យឈ្មោះ **អ ស** វាយនឹងឈ្នូកឫស្សី រួចក៏ទាញដៃកូនខ្លួនឡើងទៅលើទូក ខ្លួនពុំបានវាយគេទេ ហើយសំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង បើគេទាមទារជម្ងឺចិត្តពីខ្លួន ៗក៏ទាមទារជម្ងឺចិត្តពីគេវិញដែរ គិតជាប្រាក់ចំនួន ៨០ម៉ឺនរៀល ។

-ជនជាប់ឈ្មោះ **ល យ** បានឆ្លើយថា : ពេលកើតហេតុនោះនាង **ស ឧ** បានវាយខ្លួនបែកក្រចកដៃ រួចកូនរបស់គាត់ឈ្មោះ **ស អស** ក៏បានវាយខ្លួនដែរ រួចចាប់បោចសក់ខ្លួនជ្រមុចទឹកថែមទៀត ហើយបងរបស់ខ្លួនឈ្មោះ **ល អស** ក៏អុំទូកទៅយកខ្លួន ហើយខ្លួនក៏មកព្យាបាលនៅមន្ទីរពេទ្យស្រុកពញាឮ ខ្លួនសំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង បើគេទាមទារជម្ងឺចិត្តពីខ្លួន ខ្លួនក៏ទាមទារវិញដែរ ។

-ជនជាប់ចោទឈ្មោះ **ស អស** បានឆ្លើយថា : ខ្លួនបានវាយគ្នាទៅវិញទៅមកជាមួយឈ្មោះ **ល យ** មែនតែពុំបានត្រូវចំខ្លួនទេ គឺត្រូវតែឈើទៅវិញទៅមក នាង **ល យ** ក៏ច្រានម្តាយខ្លួនធ្លាក់ទឹក ហើយខ្លួនក៏ទៅស្រង់គាត់ឃើញបែកក្បាល ។

-ជនរងគ្រោះឈ្មោះ **ស ឧ** បានឆ្លើយថា : រឿងហេតុដំបូងមកពីវាយមងជាន់លើគ្នា រួចក៏ជេរគ្នាទៅវិញទៅមក ពេលនោះឈ្មោះ **ល យ** ក៏វាយខ្លួនចំក្បាលធ្លាក់ទឹក រួចវាឡើងមកលើទូកខ្លួន ហើយខ្លួនក៏មកព្យាបាលនៅមន្ទីរពេទ្យ សុខ សាន្ត ហើយខ្លួនសុំទាមទារជម្ងឺចិត្តជាប្រាក់ ៥០ម៉ឺនរៀល ។



Scanned with CamScanner

-ឈ្មោះ ឈ អស ជាកូនរបស់ឈ្មោះ ឈ ម បានឆ្លើយថា : មុនដំបូងនាង ស ឧ បានវាយដៃប្អូន
ខ្លួនក៏ឃាត់ ហើយគេក៏ចាប់ដៃប្អូនខ្លួនអូសតាមទូកគេ ខ្លួនក៏អុំទូកទៅយកប្អូនខ្លួនមកវិញ ។

-ឈ្មោះ ស ត ជាកូនរបស់ឈ្មោះ ស ឧ បានឆ្លើយថា : ពេលកើតហេតុខ្លួននៅលើទូក ខ្លួនឃើ
ឈ យ ប្រតាយជាមួយឈ្មោះ ស អស ម្តាយខ្លួនក៏ចូលទៅឃាត់ ហើយប្អូនរបស់ខ្លួនកាន់ឫស្សី ហើយនាង
កាន់ច្រវ៉ាទូកវាយគ្នាទៅវិញទៅមក តែពុំដឹងត្រូវត្រង់ណាទេ ក្រោយមកនាង ឈ យ ក៏វាយម្តាយរបស់ខ្លួ
ព្រមទាំងម្តាយរបស់គេឈ្មោះ ឈ ម រួចក៏ច្រានម្តាយរបស់ខ្លួនទំលាក់ទៅក្នុងទឹក ខ្លួនក៏ទៅស្រង់មកវិញ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន : ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ជនរងគ្រោះ សា
ស្តាប់អំណានលិខិតកោសល្យវិច្ច័យវេជ្ជសាស្ត្រ សន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឈ យ ឈ្មោះ
និងឈ្មោះ ស អស ពីបទបង្ករបួសស្នាមដោយចេតនាប្រាកដមែន ហើយសម្រេចតំកល់ការចោទប្រកា
ត្រឹមត្រូវតាមច្បាប់ និងសុំឱ្យតុលាការសម្រេចទៅតាមច្បាប់ចុះ ។

-ជនជាប់ចោទឈ្មោះ ឈ ម ឈ្មោះ ឈ យ និងឈ្មោះ ស អស បានសំណូមពរឱ្យតុលាកា
យុត្តិធម៌ និង បន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ
-ក្រោយពីបានស្តាប់ចម្លើយសាក្សីឆ្លើយបំភ្លឺ
-ក្រោយពីបានពិនិត្យវត្ថុតាង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>តុលាការ</u>**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ជនជាប់ចោទទាំងអស់មានស្មារតីគ្រប់គ្រាន់នៅពេលប្រព្រឹត្តបទល្មើស ។
-យល់ឃើញថា : ឈ្មោះ ស អស អាយុ ១៤ឆ្នាំ ជាកូនរបស់នាង ស ឧ ពិតជាបានវាយទៅវ
ជាមួយនាង ឈ យ ដោយកំសួលមងបណ្តាលឱ្យនាង ឈ យ របួសដោយបែកក្រចកប្រាកដមែន
-យល់ឃើញថា : រឿងហេតុដែលកើតឡើងនោះបណ្តាលមកពីជនរងគ្រោះ មិនចេះសណ្តោសប្រ
យករឿងបន្តិចបន្តួចធ្វើជាមូលដ្ឋានបង្កទំនាស់ រហូតមានរបួសបន្តិចបន្តួចរៀង១ខ្លួន ។
-យល់ឃើញថា : នាង ឈ យ ជាមនុស្សឃោឃៅវាយក្បាលនាង ស ឧ ជាជនរងគ្រោះរួ
ជនរងគ្រោះត្រូវឈ្មោះ ឈ ម ជាម្តាយច្រានទម្លាក់ទឹក បានព្រួតគ្នាវាយទៅលើ ស ឧ ថែមទៀ
-យល់ឃើញថា : អំពើរបស់ជនជាប់ចោទទាំងអស់ ដែលប្រព្រឹត្តកន្លងទៅនោះ ធ្វើឱ្យប៉ះព
របៀបរៀបរយសាធារណៈ និងនីត្យានុកូលភាពរបស់សង្គម ជាហេតុឱ្យជនរងគ្រោះខាតបង់ពេ
ក្នុងការរកស៊ី ។
-យល់ឃើញថា : តាមលិខិតបញ្ជាក់លេខ : ២៣៧/៩៥ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៥ រប



Scanned with CamScanner

ស្រុកពញាឮ ដែលបានញាក់លើជនរងគ្រោះឈ្មោះ **យ ល** បានបញ្ជាក់ថា បានចូលថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៥ ចេញថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៥ ឃើញមានរបួសរបើកក្រចកមួយ. ជាំហើមកំភួនដៃឆ្វេង ។ សន្និដ្ឋាន : របួសបានជាសះស្បើយហើយ ។

-យល់ឃើញថា : តាមលិខិតបញ្ជាក់លេខ ៣៧៨/៩៥ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥ របស់ពេទ្យគ្លីនិច សុខ សាន្ត បានបញ្ជាក់លើជនរងគ្រោះឈ្មោះនាង **ស ឧ** ថាជនរងគ្រោះបានចូលថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៥ មានស្នាមរបួសក្បាល តែពុំបានដេរនៅគ្លីនិចទេ ជាំដើមដៃ ០៣សង់ទីម៉ែត និងសន្និដ្ឋានថាជនរងគ្រោះជាសះស្បើយក្នុងរយៈពេលមួយសប្តាហ៍ ។

-យល់ឃើញថា : មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះនាង **ល ម** និង **ល យ** ពិតជាបានរួមគ្នាវាយទៅលើនាង **ស់ ឧ** ជាជនរងគ្រោះបណ្តាលឱ្យមានរបួសប្រាកដមែន ប្រព្រឹត្តនៅភូមិទួលងោក ឃុំកំពុងហ្លួង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ។

-យល់ឃើញថា : មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះនាង **អ សអ** ពិតជាបានវាយនាង **ល យ** បណ្តាលឱ្យមានរបួសស្នាមប្រាកដមែន ប្រព្រឹត្តនៅភូមិទួលងោក ឃុំកំពុងហ្លួង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ។

-យល់ឃើញថា : ជនជាប់ចោទឈ្មោះនាង **ស អស** ជាអនីតិជនទើបតែអាយុ ១៤ឆ្នាំ ប៉ុណ្ណោះ ដូច្នេះនាង **ស ឧ** ជាម្តាយត្រូវទទួលខុសត្រូវនូវសំណងរដ្ឋប្បវេណី ។

-យល់ឃើញថា : ជនរងគ្រោះនាង **ស ឧ** និងនាង **ល យ** បច្ចុប្បន្នរបួសស្នាមបានជាសះស្បើយអស់ហើយ ពុំបណ្តាលឱ្យពិការអ្វីឡើយ ។

-យល់ឃើញថា : ជនរងគ្រោះនាង **ស ឧ** ប្តឹងទាមទារជម្ងឺចិត្ត និងថ្លៃព្យាបាលជម្ងឺចំនួន ៥០ម៉ឺនរៀល ចំណែកនាង **ល ម** ទាមទារចំនួន ៨០ម៉ឺនរៀល តុលាការនឹងពិចារណា ។

## ហេតុដូច្នេះសំរេច

១-ផ្តន្ទាទោស :

អោយជនជាប់ចោទឈ្មោះនាង **ស អស** អាយុ ១៤ឆ្នាំ រួចផុតពីការចោទប្រកាន់ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះនាង **ល ម** អាយុ ៤៥ឆ្នាំ និង **ល យ** អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០២ខែ ប៉ុន្តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ០៥ឆ្នាំ ទោសព្យួរនេះគិតពីថ្ងៃប្រកាសសាលក្រមពីបទ : **បង្ករបួសស្នាមដោយចេតនា** លើនាង **ស ឧ** កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៥ ប្រព្រឹត្តនៅភូមិទួលងោក ឃុំកំពុងហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤៣, ៧០ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះនាង **ល ម** និងនាង **ល យ** រួមគ្នាបង់ជម្ងឺចិត្តទៅឱ្យទៅនាង **ស ឧ** ជាជនរងគ្រោះចំនួន ០៥ម៉ឺនរៀល ( ប្រាំម៉ឺនរៀល) ។ សុំលើសពីនេះលើកចោល ។

Scanned with CamScanner

៤-បង្គាប់ឱ្យនាង **ស ឧ** ជាម្ដាយរបស់នាង **ស អស** បង់ជម្ងឺចិត្តទៅឱ្យនាង **ល យ** ចំនួន ០២ម៉ឺនរៀល (ពីរម៉ឺនរៀល) ។ សុំលើសពីនេះលើកចោល ។

បើជនជាប់ចោទឈ្មោះនាង **ល ម** និងនាង **ល យ** គ្មានប្រាក់សងធនទណ្ឌគ្រប់ទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ : ១៨ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

៥-វត្ថុតាងមាន :

-ក្តារបន្ទះប្រវែង ០៤តឹក

-កំសួលធ្វើពីឫស្សីប្រវែង ០៣តឹកកន្លះ

ត្រូវរឹបអូសបំផ្លាញចោល ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្ដីសម្រេចនេះ ព្រះករុណាជាម្ចាស់ ជាជីវិតតំកល់លើត្បូងត្រាស់បង្គាប់ មកអាជ្ញាធរគ្រប់ជាន់ថ្នាក់យកចិត្តទុកដាក់អនុវត្តសាលក្រម ឬ សេចក្ដីសម្រេចឱ្យមានប្រសិទ្ធិភាពបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

**អនុប្រធានតុលាការ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner